សលាកបត្រព័ត៌មាន

# ផ្លូវបំបែក

ការសិក្សាអំពីផ្នត់គំនិតសង្គម
លើការចែកផ្លូវគ្នា
ការលែងលះ
និងសិទ្ធិស្ត្រីនៅកម្ពុជា

# ១

# ឧបសគ្គ និងកត្តាជំរុញ នៃការលែងលះ

## មូលហេតុដែលស្ត្រីស្វែងរកការលែងលះ (‘កត្តាជំរុញ’)

## អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល (IPV)

សម្រាប់ស្ត្រីកម្ពុជា កត្តាជំរុញចម្បងដែលរកឃើញគឺអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល (IPV) អាកប្បកិរិយាក្នុងទំនាក់ទំនងស្និទ្ធស្នាលដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត រួមទាំងអំពើបំពានលើរាងកាយ ការបង្ខិតបង្ខំផ្លូវភេទ ការរំលោភបំពានផ្លូវចិត្ត និងហិរញ្ញវត្ថុ។ ខណៈបុរសកត្តាចម្បងនៃស្វែងរកការលែងលះនោះគឺ "ការអស់មនោសញ្ចេតនាស្នេហា"។

## ការរំលោភបំពាន លើរាងកាយ

អ្នកចូលរួមការស្រាវជ្រាវជាច្រើនពិពណ៌នាថាអតីតស្វាមីបានរំលោភបំពានលើរាងកាយជាពិសេសនៅពេលប្រច័ណ្ឌឬមិនពេញចិត្តកើតឡើង៖

*គួរកត់សម្គាល់ថា ប្រភេទនៃ អំពើហិង្សាផ្លូវកាយដែលបានពិពណ៌នាដោយអ្នកចូលរួម រួមមានការវាយដំដែលបណ្តាលឲ្យមានស្នាមជាំ(DW2) "ការរុញច្រានទិងទះកំផ្លៀង"(DW13) រហូតឈានដល់អំពើហិង្សាធ្ងន់ធ្ងរ ដូចជាការដាល់ចំកណ្តាលមុខ និងការបណ្តាលឲ្យបាត់បង់ ទារកដែលមិនទាន់កើតដោយសារតែ ការរលូតកូន (DW6)។*

## ការរំលោភបំពានផ្លូវចិត្ត

ជាការពិតណាស់អាកប្បកិរិយាត្រួតត្រាហួសហេតុគឺជាមូលបទលេចធ្លោមួយនៅក្នុងទិន្នន័យ៖

*“អតីតស្វាមីរបស់ខ្ញុំមិនអនុញ្ញាតឱ្យ ខ្ញុំសម្រេចចិត្តលើអ្វីនោះទេ។ គាត់ថែមទាំងដាក់បម្រាមគោចរ... [ហើយ] ខ្ញុំមិនអាចទិញសម្លៀកបំពាក់ថ្មីឬគ្រឿងអលង្ការបានទេ ” (DW6)។*

## អំពើ រំលោភបំពានផ្នែកហិរញ្ញវត្ថុ

*“[ការលែងលះ]គឺដោយសារតែគាត់មិនបានជួយដោះស្រាយបញ្ហារបស់យើង។ ឧទាហរណ៍ខ្ញុំត្រូវសងបំណុលតែម្នាក់ឯង ហើយគាត់មិនព្រមចែករំលែកបន្ទុកនោះទេ។ ដូច្នេះ ហេតុអ្វីបានជាខ្ញុំនៅតែនៅជាមួយគាត់? បើខ្ញុំត្រូវដោះស្រាយបញ្ហាតែ ម្នាក់ឯងរស់នៅតែម្នាក់ឯងគឺល្អជាងមែនទេ? នោះជាអ្វីដែលខ្ញុំបានគិត” (DW19)។*

## អំពើហិង្សាផ្លូវភេទ

អំពើរំលោភផ្លូវភេទក្នុងចំណងអាពាហ៍ពិពាហ៍ក៏រំលេចឡើងនៅក្នុងទិន្នន័យ ដោយអ្នកឆ្លើយតបសំណួរជាច្រើនថាជាកត្តាជំរុញឱ្យមានការលែងលះ៖

*“គាត់បានចាប់រំលោភខ្ញុំដោយបង្ខំក្នុងយប់មង្គលការរបស់យើង... ជាអកុសលខ្ញុំមានផ្ទៃពោះពីសកម្មភាពរំលោភនោះ ដូច្នេះខ្ញុំគ្មានជម្រើសអ្វីក្រៅពីនៅជាមួយគាត់... ខ្ញុំកាន់តែភ័យខ្លាច ហើយជឿថាខ្ញុំគ្មានផ្លូវចេញ... ខ្ញុំទ្រាំរស់នៅក្នុងស្ថានភាពនោះយ៉ាងយូរ រហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺ ហើយចង់នៅឆ្ងាយពីគាត់” (CW4)។*